**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**
លេខ : ០៨៥/០០៨ /២០០៤
ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៤
**សេចក្តីសម្រេច**
លេខ : ០៦៣/០០៥/២០០៤ កបធ.ច
ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៤

# ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញលិខិតចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៤ របស់តំណាងរាស្ត្រចំនួន ១៣ រូប ដែលស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃមាត្រា ៦៣ នៃបទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និង នីតិវិធីព្រហ្មទណ្ឌសំរាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**
**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

-យល់ឃើញថា តំណាងរាស្ត្រចំនួន ១៣ រូប បានធ្វើលិខិតមួយ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៤ មកឯកឧត្តមប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃមាត្រា ៦៣ នៃបទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និង នីតិវិធីព្រហ្មទណ្ឌសំរាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃខែឆ្នាំដដែល វេលាម៉ោង ១៤:២០ ល្ងាច ។ តំណាងរាស្ត្រជាម្ចាស់សំណើចំនួន ១៣ រូបនេះ គឺគ្រប់គ្រាន់តាមបទបញ្ញត្តិនៃមាត្រា ១៤១ ថ្មីនៃរដ្ឋធម្មនុញ្ញហើយ ។ ដូច្នេះក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញភាពនេះមកពិនិត្យបាន ដោយស្របតាមមាត្រា ១៣៦ ថ្មី មាត្រា ១៤១ ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៥ មាត្រា ១៨ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ។

-យល់ឃើញថា សំណើរបស់តំណាងរាស្ត្រចំនួន ១៣ រូប បានលើកឡើងថា *បទបរិហារកេរ្តិ៍ និងជេរប្រមាថដែលមានចែងក្នុងមាត្រា ៦៣ នៃបទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និង នីតិវិធីព្រហ្មទណ្ឌសំរាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល បានអនុម័តដោយឧត្តមក្រុមប្រឹក្សាជាតិជាន់ខ្ពស់នៃកម្ពុជា តាំងពីថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ មកម្លេះ ។ នៅឆ្នាំ ១៩៩៣ សភាធម្មនុញ្ញបានអនុម័តរដ្ឋធម្មនុញ្ញកម្ពុជាថ្មីមួយ*

*ដែលបានផ្ដល់អភ័យឯកសិទ្ធិដល់សមាជិករដ្ឋសភា ដូចចែងក្នុងមាត្រា ៨០ ថា " តំណាងរាស្ត្រមានអភ័យឯកសិទ្ធិសភា ។ តំណាងរាស្ត្ររូបណាក៏ដោយ មិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬ ឃុំខ្លួន ដោយហេតុពីបានសំដែងយោបល់ ឬ បញ្ចេញមតិក្នុងការបំពេញមុខងាររបស់ខ្លួនសោះឡើយ ។...*"។ ហេតុដូច្នេះ ហើយទើបតំណាងរាស្ត្រចំនួន ១៣ រូប សុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពមាត្រា ៦៣ នៃបទបញ្ញត្តិស្ដីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និង នីតិវិធីព្រហ្មទណ្ឌសំរាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល ដែលពាក់ព័ន្ធទៅនឹងមាត្រា ៨០ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ស្ដីពីអភ័យឯកសិទ្ធិសភា ។

-យល់ឃើញថា តំណាងរាស្ត្រគ្រប់រូប មានអភ័យឯកសិទ្ធិសភា ដែលធានាមិនឱ្យតំណាងរាស្ត្របារម្ភអំពីការរំលោភបំពានពីសំណាក់អំណាចនីតិប្រតិបត្តិ ឬ អំណាចតុលាការ ។ ប៉ុន្តែអភ័យឯកសិទ្ធិនេះ ក៏មានព្រំដែនកំណត់ដែរ ។

-យល់ឃើញថា តំណាងរាស្ត្រ មិនអាចប្រើប្រាស់អភ័យឯកសិទ្ធិនេះឱ្យប៉ះពាល់ដល់សិទ្ធិអ្នកដទៃ ( មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញ ) ឬ ប្រព្រឹត្តអំពើល្មើសច្បាប់ព្រហ្មទណ្ឌ។

-យល់ឃើញថា យោងតាមខ្លឹមសារមាត្រា ៣១ មាត្រា ៣៨ មាត្រា ៣៩ និង មាត្រា ៤១ នៃរដ្ឋធម្មនុញ្ញ មាត្រា ៦៣ ស្ដីពីការបរិហារកេរ្តិ៍ និង ការជេរប្រមាថ នៃបទបញ្ញត្តិស្ដីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និង នីតិវិធីព្រហ្មទណ្ឌសំរាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល ដែលមាន ៥ វាក្យខ័ណ្ឌ ឃើញថា មិនមានចំណុចណាផ្ទុយនឹងរដ្ឋធម្មនុញ្ញទេ ។

-យល់ឃើញថា មាត្រា ១៥៨ ថ្មី ( មាត្រា ១៣៩ ចាស់) នៃរដ្ឋធម្មនុញ្ញ ចែងថា " *ច្បាប់ និង លិខិតបទដ្ឋានទាំងអស់នៅកម្ពុជា ដែលធានាការពារបាននូវទ្រព្យសម្បត្តិរដ្ឋ សិទ្ធិ សេរីភាព និង ទ្រព្យសម្បត្តិត្រឹមត្រូវតាមច្បាប់របស់បុគ្គល និង ដែលសមស្របនឹងប្រយោជន៍ជាតិ ត្រូវមានអានុភាពអនុវត្តបន្តទៅមុខទៀត រហូតដល់មានអត្ថបទថ្មីមកកែប្រែ ឬ លុបចោល លើកលែងតែបទបញ្ញត្តិណា ដែលផ្ទុយនឹងស្មារតីនៃរដ្ឋធម្មនុញ្ញនេះ ។* "។ ដូច្នេះផ្អែកលើខ្លឹមសារមាត្រា ១៥៨ ថ្មី ( មាត្រា ១៣៩ ចាស់ ) នៃរដ្ឋធម្មនុញ្ញ មាត្រា ៦៣ ស្ដីពីការបរិហារកេរ្តិ៍ និង ការជេរប្រមាថ នៃបទបញ្ញត្តិស្ដីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសំរាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល ដែលមាន ៥ វាក្យខ័ណ្ឌ ត្រូវស្ថិតនៅជាធរមាន ពីព្រោះពុំទាន់មានអត្ថបទថ្មីមកកែប្រែ ឬលុបចោលនូវបទបញ្ញត្តិនៃមាត្រានេះទេ ។

## **សម្រេច**

**មាត្រា ១.-** មាត្រា ៦៣ ស្ដីពីការបរិហារកេរ្តិ៍ និង ការជេរប្រមាថ នៃបទបញ្ញត្តិស្ដីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និង នីតិវិធីព្រហ្មទណ្ឌសំរាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល ដែលមាន ៥ វាក្យខ័ណ្ឌ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

**មាត្រា ២.-** សេចក្ដីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ និង ជាសេចក្ដីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៤

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ប៊ិន ឈិន**